# ព្រះរាជក្រម

នស/រកម/១២០២/ ០២០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ១ ។

ច្បាប់នេះមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

**មាត្រាតែមួយ :**

មាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ២៦ ថ្មី.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំគម្រោងចំណូល និងគំរោងចំណាយថវិកាតាមប្រតិទិនដូចខាងក្រោមនេះ :

នៅខែ ឧសភា រៀងរាល់ឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំនូវទស្សនវិស័យនៃថវិកាឆ្នាំបន្ទាប់ និងរៀបចំនូវគម្រោងចំណូល ចំណាយថវិកាសរុប ដែលមានលក្ខណៈជាសេចក្តីព្រាងបឋមនៃគម្រោងថវិកា ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ ដោយផ្អែកលើមូលដ្ឋានគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល និងលើការវិភាគនៃសមោកាសសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្មតិកម្មទាំងឡាយនៃការវិវត្តនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច នៅក្នុងរយៈពេលខ្លី និងរយៈពេលមធ្យមដែលអាចកើតមានឡើង ។

សេចក្តីព្រាងបឋមនៃគម្រោងថវិកា មានរូបភាពជាការណែនាំដែលបញ្ជាក់អំពីការកំណត់លក្ខខណ្ឌទាំងឡាយ សម្រាប់រៀបចំគម្រោងថវិកានៃឆ្នាំបន្តបន្ទាប់ ការវិភាគទិន្នន័យសំខាន់ៗនៃសមោកាសសេដ្ឋកិច្ចទូទៅ និងផលវិបាកទាំងឡាយដែលអាចកើតមានឡើង ដើម្បីធានាតុល្យភាពជាមូលដ្ឋាន និងការកំណត់កញ្ចប់ថវិការួម និងកញ្ចប់ថវិកាតាមស្ថាប័ននីមួយៗ។

ព្រមជាមួយគ្នានេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំនូវសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ជូននូវទម្រង់បែបបទ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញ និងឯកសារយុត្តិការដែលត្រូវភ្ជាប់មកជាមួយ ហើយផ្ញើជូនក្រសួង ស្ថាប័ន និងខេត្ត ក្រុង នៅដំណាច់ខែ មិថុនា ដើម្បីរៀបចំនូវគម្រោងចំណូល ចំណាយថវិការបស់ខ្លួន ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលគ្រប់ខេត្ត ក្រុង ត្រូវរៀបចំនូវគម្រោងចំណូលចំណាយថវិការបស់ខ្លួន សម្រាប់រដ្ឋបាលកណ្តាល សម្រាប់មន្ទីរជំនាញរបស់ខ្លួន នៅតាមខេត្ត ក្រុង និងអង្គភាពដទៃទៀតក្រោមឱវាទ ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីព្រាងបឋមដែលគណៈរដ្ឋមន្ត្រីបានសម្រេច និងសារាចរណែនាំបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ គម្រោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយឺតបំផុត ត្រឹមថ្ងៃទី ២៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូល ចំណាយថវិការបស់ក្រសួង ស្ថាប័ន និងខេត្ត ក្រុង ដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអញ្ជើញរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលគ្រប់ខេត្ត ក្រុង មកពីភាក្សាការពារគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូលចំណាយថវិកាទាំងនោះ ឱ្យសមស្របតាមបទប្បញ្ញត្តិនៃការណែនាំថវិកា ដោយមានកាត់បន្ថយចំណាយណាដែលមិនចាំបាច់ និងបង្កើនចំណូល ឱ្យបានសមស្រប ។

នៅក្នុងអំឡុងខែ កញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការប្រមូលសរុបដើម្បីធ្វើតុល្យភាពចំណូល ចំណាយថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

នៅសប្តាហ៍ទី ១ នៃខែតុលា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ សម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី ១ នៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទី ១ នៃខែ ធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះ ត្រូវបានពិនិត្យអនុម័តជាស្ថាពរ មុនថ្ងៃទី ២៥ ខែ ធ្នូ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

នស/រកម.១២០២.០០៣៧៥ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ០២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុំ ម៉ានិត**